ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# កម្មវិធីសិក្សាលម្អិត

មុខវិជ្ជា

# អក្សរសាស្ត្រខ្មែរ

សម្រាប់

## កម្រិតមធ្យមសិក្សាទុតិយភូមិ

២០១៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ៥០៤ អយក.ប្រក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជា កម្រិតមធ្យមសិក្សាទុតិយភូមិ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញប្រកាសលេខ៣០២ អយក.ប្រក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស
- តាមសំណើរបស់គណៈកម្មការនិងអនុគណៈកម្មការកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល

## សម្រេច

**ប្រការ១.-**

ប្រកាសដាក់ឱ្យប្រើជាផ្លូវការ "**កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាទុតិយភូមិ**" ។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

**ប្រការ២ .-**

កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាទុតិយភូមិនេះ មានមាតិកាសំខាន់ៗ ដូចខាងក្រោម៖

- សេចក្តីផ្តើម
- គោលបំណង
- គោលគំនិតសំខាន់ៗ
- របាយម៉ោងសិក្សា
- ការណែនាំអនុវត្ត
- ការវាយតម្លៃ
- តារាងកម្មវិធីសិក្សា

ខ្លឹមសារលម្អិតនៃកម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាទុតិយភូមិជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ .-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ និងអ្នកពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួង អយក
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ អគ.អរ

# បុព្វកថា

ការអប់រំជាវិស័យគន្លឹះមួយក្នុងការរួមចំណែកអភិវឌ្ឍធនធានមនុស្ស សំដៅជំរុញឱ្យសង្គមនិងសេដ្ឋកិច្ចរីកចម្រើន។ បច្ចុប្បន្ននេះ សង្គមនិងសេដ្ឋកិច្ចមានការអភិវឌ្ឍនិងការរីកចម្រើនដែលជាកម្លាំងចលករជំរុញឱ្យមានការកែលម្អការអប់រំ ដើម្បីអាចឆ្លើយតបទៅនឹងការវិវត្តថ្មីៗរបស់សង្គមនិងសេដ្ឋកិច្ច។ ប៉ុន្មានទសវត្សរ៍ចុងក្រោយនៃសតវត្សរ៍ទី២០និងដើមសតវត្សរ៍ទី២១នេះ សង្គមនិងសេដ្ឋកិច្ចឈានដល់បរិបទថ្មីដែលមិនធ្លាប់មានកន្លងមកដោយពិភពលោកកាន់តែបើកចំហ ការប្រកួតប្រជែងកាន់តែស្រួចស្រាល់ជាងមុន វិស័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រកាន់តែទំនើបនិងប្រសើរឡើង។ កត្តាទាំងនេះនាំឱ្យប្រទេសឬជាតិសាសន៍នានាខិតខំពង្រឹងធនធានមនុស្សរបស់ខ្លួន ដើម្បីតាមឱ្យទាន់និងអាចឈរជើងប្រកបដោយឧត្តមភាពក្នុងបរិបទថ្មីនៃសង្គមនិងសេដ្ឋកិច្ចរបស់ពិភពលោក។

ដើម្បីឆ្លើយតបនឹងតម្រូវការរីកចម្រើនរបស់សង្គមនិងសេដ្ឋកិច្ចថ្មី ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវការកែទម្រង់កម្មវិធីសិក្សាអប់រំចំណេះទូទៅដែលជាមូលដ្ឋានសម្រាប់ឱ្យអ្នកសិក្សាអាចបន្តការសិក្សា និងទទួលការបណ្ដុះបណ្ដាលផ្សេងៗទៀត សំដៅលើកកម្ពស់គុណភាពធនធានមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ដែលជាធាតុសំខាន់ក្នុងកម្មវិធីសិក្សា។ កម្មវិធីសិក្សាលម្អិតនេះចែកជាបីភូមិសិក្សាដាច់ដោយឡែកពីគ្នាតែប្រទាក់ក្រឡានិងគាំទ្រគ្នា។ កម្មវិធីសិក្សាលម្អិតកម្រិតមធ្យមសិក្សាទុតិយភូមិនេះ បានបន្ថែមម៉ោងសិក្សាច្រើនជាងមុនទៅក្នុងកម្មវិធីសិក្សា។ ការកែទម្រង់កម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ សំដៅកសាងមូលដ្ឋានគ្រឹះសម្រាប់ការអប់រំនៅកម្រិតបន្តដោយពង្រីកវិសាលភាពចំណេះដឹង បំណិនការអប់រំសីលធម៌ គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព ព្រមទាំងផ្ដល់នូវចំណេះដឹងមូលដ្ឋានផ្នែកបច្ចេកវិទ្យា បំណិនសតវត្សរ៍ទី២១ និងបំណិនសិក្សាពេញមួយជីវិត ដើម្បីឱ្យក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។

ក្រសួង សង្ឃឹមយ៉ាងមុតមាំថា កម្មវិធីសិក្សាលម្អិតនេះនឹងបម្រើជាប្រយោជន៍ដ៏មានប្រសិទ្ធភាពក្នុងការអភិវឌ្ឍសៀវភៅសិក្សាគោល សម្ភារៈឧបទេស ឯកសារជំនួយនានាក្នុងការរៀននិងបង្រៀន និងឧបករណ៍ពិនិត្យតាមដាន វាយតម្លៃផ្សេងៗ។

ក្រសួង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអនុគណៈកម្មការមុខវិជ្ជាឯកទេសទាំងអស់ លេខាធិការដ្ឋានកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមនិងដើរតួនាទីស្នូលក្នុងការសម្របសម្រួល ព្រមទាំងដឹកនាំរៀបចំតាក់តែងកម្មវិធីសិក្សាលម្អិតនេះឱ្យបានសម្រេចជាផ្លែផ្កាឡើងនាពេលនេះ។

ថ្ងៃ អង្គារ ៧រោច ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

# អារម្ភកថា

ដើម្បីលើកកម្ពស់គុណភាពអប់រំនៅកម្ពុជា ឱ្យទាន់ការអភិវឌ្ឍនៃប្រទេសជាតិ ការរីកចម្រើនរបស់ប្រទេសនានាក្នុងតំបន់ និងសាកលលោក ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់កម្មវិធីសិក្សាជាបន្តបន្ទាប់ពិសេសក្រសួង បានអភិវឌ្ឍជាស្ថាពរនូវក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ សម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាអប់រំចំណេះទូទៅ និងបច្ចេកទេស។ ដូច្នេះការអភិវឌ្ឍកម្មវិធីសិក្សាលម្អិតមុខវិជ្ជាអក្សរសាស្ត្រខ្មែរ សម្រាប់មធ្យមសិក្សាទុតិយភូមិថ្នាក់ទី១០ដល់ទី១២ ជាការចាំបាច់ ដើម្បីផ្តល់លទ្ធភាពឱ្យសិស្សបានសិក្សាកាន់តែស៊ីជម្រៅ ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ទាំងក្នុងការប្រើប្រាស់ប្រចាំថ្ងៃ ទាំងក្នុងការសិក្សាបន្ត និងការឈោងចាប់យកអាជីព។

កម្មវិធីសិក្សាលម្អិតនេះបង្ហាញពីសាវតារ ការកែទម្រង់កម្មវិធីសិក្សា ខ្លឹមសារសំខាន់ៗ ប្រភេទអត្ថបទផ្សេងៗ កំណាព្យ ចម្រៀង ច្បាប់ទូន្មានផ្សេងៗ និមិត្តសញ្ញាជាតិ តែងសេចក្តី វេយ្យាករណ៍ អក្សរសិល្ប៍ខ្មែរ អក្សរសិល្ប៍បរទេស សិក្សាអត្ថបទអក្សរសិល្ប៍។ ក្រៅពីនេះ មានប្រធានបទ និងបំណិនចាំបាច់ផ្សេងៗទៀត ដែលផ្សារភ្ជាប់នឹងជីវភាពជាក់ស្តែងដូចជា ការចងក្រងឯកសារ ការធ្វើផែនការ ការធ្វើគម្រោង ការធ្វើបទបង្ហាញ សម្ភាស វាគ្មិន ការថ្លែងសុន្ទរកថា បាឋកថា ការប្រើប្រាស់ប្រព័ន្ធបណ្តាញសង្គម។ល។ ទន្ទឹមនឹងនោះក៏មានបំណិនសំណេរអនុវត្ត ដែលជាបំណិនប្រចាំថ្ងៃដូចជា ការសរសេររបាយការណ៍ កំណត់ហេតុ សន្ទរកថា វិយោគកថា បទវិចារណកថា និងលិខិតផ្សេងៗទៀត។ ក្រៅពីនេះឯកសារនេះក៏បានបង្ហាញពី ការណែនាំអនុវត្ត ការប្រើប្រាស់សម្ភារឧបទេស វិធីសាស្ត្របង្រៀន របាយម៉ោងសិក្សាតាមបណ្តុំវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម និងលទ្ធផលសិក្សារំពឹងទុក(វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា) និងការវាយតម្លៃ ដែលមានលក្ខណៈងាយស្រួល ក្នុងការអនុវត្តប្រកបដោយគុណភាព។

អនុគណៈកម្មការមុខវិជ្ជាឯកទេសអក្សរសាស្ត្រខ្មែរសង្ឃឹមថា កម្មវិធីសិក្សាលម្អិតមុខវិជ្ជាអក្សរសាស្ត្រខ្មែរនេះជាគោលលំអានសម្រាប់ការរៀបចំសៀវភៅសិក្សាគោល ការវាយតម្លៃ សម្ភារឧបទេស វិធីសាស្ត្របង្រៀន និងឯកសារជំនួយផ្សេងៗ ក្នុងការអភិវឌ្ឍវិស័យអប់រំមួយ ដែលមានការចូលរួមពីសំណាក់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស មាតាបិតា សហគមន៍ និងដៃគូអភិវឌ្ឍន៍ដទៃទៀត ដើម្បីលើកកម្ពស់ការអប់រំនៅកម្ពុជាឱ្យមានការអភិវឌ្ឍដូចប្រទេសនានាក្នុងតំបន់និងលើសកលលោក។

**អនុគណៈកម្មការមុខវិជ្ជាឯកទេសអក្សរសាស្ត្រខ្មែរ**

# មាតិកា


ប្រកាស........................................................................................................ i

បុព្វកថា........................................................................................................ iii

អារម្ភកថា........................................................................................................ iv

មាតិកា........................................................................................................ v

១- សេចក្តីផ្តើម........................................................................................................ 1

២- គោលបំណង........................................................................................................ 2

៣- គោលគំនិតៗសំខាន់ៗ........................................................................................................ 3

៤- របាយម៉ោងសិក្សា........................................................................................................ 4

៥- ការណែនាំអនុវត្ត........................................................................................................ 7

៦- ការវាយតម្លៃ........................................................................................................ 8

៧- តារាងកម្មវិធីសិក្សា........................................................................................................ 11

៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១០........................................................................................................ 12

៧.២- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១១........................................................................................................ 30

៧.៣- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១២........................................................................................................ 52

៨- ឯកសារយោង........................................................................................................ 72

៩- បញ្ជីឈ្មោះគណៈកម្មការ........................................................................................................ 73

# ១- សេចក្ដីផ្ដើម

## ១.១- សាវតារ

ក្រសួងអប់រំ យុវជននិងកីឡា បានធ្វើកំណែទម្រង់កម្មវិធីសិក្សា ជាបន្តបន្ទាប់ច្រើនលើកច្រើនគ្រាមកហើយ។ ដំណាក់កាលទី១ ចាប់ពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៦ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តប្រព័ន្ធអប់រំ១០ឆ្នាំ គឺនៅបឋមសិក្សា៤ឆ្នាំ មធ្យមសិក្សាបឋមភូមិ៣ឆ្នាំ និងមធ្យមសិក្សាទុតិយភូមិ៣ឆ្នាំ។ ដំណាក់កាលនេះ វិស័យអប់រំយើងបានប្រមែប្រមូលអ្នកចេះដឹង ដែលនៅសល់ពីការសម្លាប់នៃរបបកម្ពុជាប្រជាធិបតេយ្យមកធ្វើជាគ្រូបង្រៀន ដោយអនុវត្តគោលការណ៍ អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះសោះ។ ដំណាក់កាលទី២ ចាប់ពីឆ្នាំ១៩៨៧ដល់ឆ្នាំ១៩៩៦ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់ប្រព័ន្ធអប់រំចំណេះទូទៅ ដោយប្ដូរពីប្រព័ន្ធអប់រំ១០ឆ្នាំ មកអនុវត្តប្រព័ន្ធអប់រំ១១ឆ្នាំ គឺនៅបឋមសិក្សា៥ឆ្នាំ មធ្យមសិក្សាបឋមភូមិ៣ឆ្នាំ និងមធ្យមសិក្សាទុតិយភូមិ៣ឆ្នាំ។ ក្នុងដំណាក់កាលនេះ យើងបានធ្វើការកែលម្អបន្ថែមលើរបាយម៉ោងសិក្សា និងខ្លឹមសារសំខាន់ៗ មួយចំនួន ជាពិសេសបានពង្រឹងនិងពង្រីកទៅលើផ្នែកភាសាខ្មែរនិងអក្សរសាស្ត្រជាតិខ្មែរ។ ដំណាក់កាលទី៣ ចាប់ពីឆ្នាំ១៩៩៧ដល់ឆ្នាំ២០០៤ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់ប្រព័ន្ធអប់រំ ដោយបានប្ដូរពីប្រព័ន្ធអប់រំ១១ឆ្នាំ មកអនុវត្តប្រព័ន្ធអប់រំ១២ឆ្នាំ គឺនៅបឋមសិក្សា៦ឆ្នាំ មធ្យមសិក្សាបឋមភូមិ៣ឆ្នាំ និងមធ្យមសិក្សាទុតិយភូមិ៣ឆ្នាំ។ ក្នុងដំណាក់កាលនេះ បានកែសម្រួលលើ ទម្រង់ មុខវិជ្ជា របាយម៉ោង ខ្លឹមសារ វិធីសាស្ត្រ និងការអនុវត្ត។ ដំណាក់កាលទី៤ ចាប់ពីឆ្នាំ២០០៥ដល់ឆ្នាំ២០១៥ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់ និងបានធ្វើបច្ចុប្បន្នភាពលើកម្មវិធីសិក្សាជាបន្តបន្ទាប់ថែមទៀតគឺ សិស្សសិក្សាតាមជម្រើសមុខវិជ្ជា និងសិក្សាតាមបណ្ដុំមុខវិជ្ជា មានបណ្ដុំវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម។ ដំណាក់កាលទី៥ នៅក្នុងឆ្នាំ២០១៦ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់មួយលើកទៀត គឺបានអភិវឌ្ឍក្របខណ្ឌកម្មវិធីសិក្សា និងកម្មវិធីសិក្សាថ្មីគ្រប់មុខវិជ្ជា ព្រមទាំងបានបន្ថែមមុខវិជ្ជាមួយចំនួនទៀត។ ក្នុងដំណាក់កាលនេះ បានកែសម្រួលលើទម្រង់ មុខវិជ្ជា របាយម៉ោង ខ្លឹមសារ វិធីសាស្ត្រ និងការអនុវត្ត សំដៅធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ននិងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត ព្រមទាំងធ្វើឱ្យស្របតាមការវិវឌ្ឍយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចសង្គម និងវប្បធម៌ ក្នុងតំបន់និងអន្តរជាតិ។

## ១.២- ការកែទម្រង់កម្មវិធីសិក្សា

ការកែទម្រង់កម្មវិធីសិក្សា ជានិន្នាការមួយស្របទៅនឹងការវិវត្តយ៉ាងលឿននៃសេដ្ឋកិច្ចសង្គមនិងវប្បធម៌កម្ពុជាក្នុងសម័យបច្ចុប្បន្ន និងស្របពេលដែលពិភពលោកមានការប្រែប្រួលយ៉ាងឆាប់រហ័ស។ ទស្សនវិជ្ជាថ្មី មានទំនោរកំណត់បញ្ចូលលទ្ធផលសិក្សា ជាគោលបំណងចម្បងក្នុងការអភិវឌ្ឍកម្មវិធីសិក្សា។ បញ្ញត្តិនៃកម្មវិធីសិក្សាបានធ្វើឱ្យមានការផ្លាស់ប្ដូរទស្សនៈ គោលគំនិត គរុកោសល្យ និងវិធីសាស្ត្របង្រៀន។ ការកែទម្រង់កម្មវិធីសិក្សា ជាផ្នែកមួយនៃកំណែទម្រង់វិស័យអប់រំនៅកម្ពុជា ដែលក្រសួងអប់រំ យុវជន និងកីឡា មានចក្ខុវិស័យ កសាងនិងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជា ឱ្យក្លាយជាសង្គមរីកចម្រើន លើផ្នែកចំណេះដឹងនិងចំណេះធ្វើជាមូលដ្ឋាន។ ដើម្បីឆ្លើយតបនឹងចក្ខុវិស័យនេះ ក្រសួងបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំពីរចំណុចគឺ(១)ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត និង(២)ធានាភាពសក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំបាន គឺត្រូវពឹងផ្អែកទៅលើសសរស្តម្ភទាំង៥មាន (១)ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (២)ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងកែលម្អបរិស្ថាន (៣)ការដាក់ឱ្យអនុវត្តអធិការកិច្ច (៤)ការពង្រឹងវង្វាយតម្លៃសិក្សាដូចជាការប្រឡង វង្វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ និង(៥)ការកែទម្រង់ឧត្តមសិក្សា។ ក្រសួងបានរៀបចំរចនាសម្ព័ន្ធដែលមានអនុវិស័យទាំង

៧ក្នុងនោះមាន (១)អនុវិស័យការអប់រំកាយនិងកីឡា (២)អនុវិស័យការអភិវឌ្ឍយុវជន (៣)អនុវិស័យការអប់រំក្រៅប្រព័ន្ធ (៤)អនុវិស័យការអប់រំឧត្តមសិក្សា (៥)អនុវិស័យការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស (៦)អនុវិស័យការអប់រំបឋមសិក្សា និង(៧)អនុវិស័យការអប់រំកុមារតូច។ ដើម្បីសម្រេចបានជោគជ័យក្នុងវិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវកម្មវិធីកំណែទម្រង់១៥ចំណុចគឺ (១)ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (២)ការពង្រាយគ្រូបង្រៀន (៣)កំណែទម្រង់មជ្ឈមណ្ឌលបណ្ដុះបណ្ដាលគ្រូបង្រៀន (៤)ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន (៥)ការងារអធិការកិច្ច (៦)វង្វាយតម្លៃលទ្ធផលសិក្សា (៧)កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ (៨)កំណែទម្រង់កម្មវិធីសិក្សានិងសៀវភៅសិក្សា (៩)ការសាងសង់អគារសិក្សានិងការជួសជុល (១០)ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា (១១)ការលើកកម្ពស់វិស័យកីឡា (១២)ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន (១៣)ការអប់រំបច្ចេកទេស (១៤)ការបង្កើតសាលារៀនជំនាន់ថ្មី និង(១៥)ការរៀបចំគន្លងអាជីព និងបណ្ដុះបណ្ដាលនាយកសាលា។

## ២- គោលបំណង

អក្សរសាស្ត្រខ្មែរ ជាអត្តសញ្ញាណនៃវប្បធម៌ និងប្រពៃណីរបស់ជាតិខ្មែរ។ ការចេះដឹង យល់ ស្គាល់ ប្រើប្រាស់ ថែរក្សា និងឱ្យតម្លៃភាសានិងអក្សរសាស្ត្រខ្មែរ ជាមោទនភាពរបស់យើង ជាពលរដ្ឋខ្មែរគ្រប់រូប។ កម្មវិធីសិក្សាលម្អិតនៅមធ្យមសិក្សាទុតិយភូមិថ្នាក់ទី១០ដល់ថ្នាក់ទី១២ មានគោលបំណងដូចតទៅ៖

- បន្តអភិវឌ្ឍសមត្ថភាពផ្នែកភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរពីមធ្យមសិក្សាបឋមភូមិ ដោយតម្រង់ទិស ការសិក្សារបស់សិស្សទៅតាមជម្រើសបណ្ដុំមុខវិជ្ជា(វិទ្យាសាស្ត្រសង្គមនិងវិទ្យាសាស្ត្រ) ដើម្បីបន្តការសិក្សា ឬចាប់យកអាជីពការងារក្នុងសង្គម។
- ផ្ដល់ដល់សិស្ស នូវការសិក្សាស៊ីជម្រៅទៅលើប្រវត្តិភាសា អក្សរ អក្សរសាស្ត្រ អក្សរសិល្ប៍ សិល្បៈ ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់របស់ជាតិ និងអន្តរជាតិមួយចំនួន។
- ផ្ដល់ការសិក្សាស៊ីជម្រៅទៅលើគ្រប់ទម្រង់ និងប្រភេទនៃអក្សរសិល្ប៍ ដោយបង្ហាញ វិភាគ វែកញែក បញ្ចេញយោបល់ធ្វើការសន្និដ្ឋាន និងវាយតម្លៃបានត្រឹមត្រូវ ប្រកបដោយភាពច្បាស់លាស់ និងសុភវិនិច្ឆ័យ។
- បណ្ដុះសិស្សឱ្យមានជំនាញ ក្នុងការទទួលព័ត៌មាន(ស្ដាប់) ការផ្ដល់ព័ត៌មានការបង្ហាញ បញ្ចេញយោបល់...(និយាយ) ការស្វែងរកព័ត៌មាន ការស្វែងយល់ ការសិក្សាស្រាវជ្រាវ...(អាន) និងការប្រើប្រាស់សំណេរគ្រប់ប្រភេទក្នុងការសិក្សាស្រាវជ្រាវ ទំនាក់ទំនងក្នុងជីវភាពប្រចាំថ្ងៃ ទីផ្សារការងារ និងអាជីព(សំណេរ)។
- បណ្ដុះសិស្សឱ្យចេះវិភាគ បានច្បាស់លាស់ ទៅលើស្នាដៃអក្សរសិល្ប៍ជាតិ និងអន្តរជាតិធំៗ ដោយបង្ហាញពីប្រវត្តិស្នាដៃ អ្នកនិពន្ធ អត្ថរូប អត្ថន័យ អត្ថរស និងគុណតម្លៃនៃស្នាដៃ។
- ប្រើប្រាស់ភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ក្នុងទំនាក់ទំនងប្រចាំថ្ងៃ កិច្ចការរដ្ឋបាល ទីផ្សារការងារ ការសិក្សាស្រាវជ្រាវ និងសិល្បៈ។
- បណ្ដុះស្មារតីសិស្សឱ្យចេះស្រឡាញ់ ថែរក្សា និងឱ្យតម្លៃទៅលើភាសា អក្សរសាស្ត្រជាតិ ប្រពៃណី ទំនៀមទម្លាប់ និងវប្បធម៌ អរិយធម៌ខ្មែរ។
- ចូលរួមអភិវឌ្ឍភាសានិងអក្សរសាស្ត្រជាតិ ឱ្យមានលក្ខណៈទំនើបទាន់សម័យ ឆ្លើយតបទៅនឹងការប្រើប្រាស់ក្នុងសង្គមរីកចម្រើន និងសកលភាវូបនីយកម្ម ។
- បណ្ដុះស្មារតីត្រិះរិះពិចារណា វិភាគរកហេតុផល វាយតម្លៃ ដោះស្រាយបញ្ហា និងអន្តរកម្មក្នុង ក្របខណ្ឌជាតិ តំបន់ និងលើសកលលោក។

## ៣- គោលគំនិតសំខាន់ៗ

### ៣.១- គោលដៅរួម

មុខវិជ្ជាអក្សរសាស្ត្រខ្មែរនៅថ្នាក់ទី១០ ទី១១ និងថ្នាក់ទី១២ ទាំងបណ្ដុំវិទ្យាសាស្ត្រ និងបណ្ដុំវិទ្យាសាស្ត្រសង្គម មានគោលដៅសិក្សាដូចតទៅ៖

- ស្ដាប់អត្ថបទព័ត៌មានជាតិ អន្តរជាតិ អត្ថបទអត្ថាធិប្បាយ អត្ថបទពាក់ព័ន្ធផ្លូវច្បាប់ ទស្សនៈ ការឃោសនា អត្ថបទអក្សរសិល្ប៍ខ្មែរ និងបរទេស ព្រមទាំងអត្ថបទផ្សេងៗទៀត ដើម្បីទទួលបានបទពិសោធ និងបង្ហាញពីគោលបំណង ទស្សនៈ ផ្នត់គំនិត ការអូស ទាញរបស់អ្នកដទៃ បន្ទាប់ពីធ្វើការវិភាគ សំយោគ វាយតម្លៃ សន្និដ្ឋាន និងវិនិច្ឆ័យប្រកបដោយគតិបណ្ឌិត។
- ពន្យល់ បកស្រាយ បញ្ចេញមតិគាំទ្រ ជំទាស់ ពង្រីកគំនិត ពិភាក្សា វែកញែក សំយោគ សន្និដ្ឋាន បង្ហាញហេតុផលបានច្បាស់លាស់ សមហេតុផល និងត្រឹមត្រូវ។
- ប្រើបច្ចេកទេសក្នុងការសម្របសម្រួល ការបញ្ចុះបញ្ចូល ការអូសទាញ ស្របតាមស្ថានភាព ជាក់ស្តែង ទាក់ទងទៅនឹងទស្សនៈ ផ្នត់គំនិត ជីវភាពសង្គម វប្បធម៌ និងសេដ្ឋកិច្ចជាដើម។
- អានដើម្បីយល់ន័យទៅលើអត្ថបទព័ត៌មានជាតិនិងអន្តរជាតិ ទស្សនៈ ពាក្យស្លោក សុភាសិត របាំ អត្ថបទអត្ថាធិប្បាយ អត្ថបទពាក់ព័ន្ធផ្លូវច្បាប់ ការឃោសនា សន្ទរកថា វិយោគកថា បទវិចារណកថា អត្ថបទអក្សរសិល្ប៍ខ្មែរ និងបរទេស ព្រមទាំងអត្ថបទផ្សេងៗទៀត។
- វិភាគកាន់តែស៊ីជម្រៅទៅលើអត្ថបទអក្សរសិល្ប៍ខ្មែរ និងបរទេសសំខាន់ៗមួយចំនួន ដោយបង្ហាញឱ្យឃើញអត្ថរូប អត្ថន័យ អត្ថរស និងគុណតម្លៃ របស់ស្នាដៃនីមួយៗ។
- អានអត្ថបទអក្សរសិល្ប៍ប្រជាប្រិយ អក្សរសិល្ប៍សម័យបុរាណ សម័យកណ្ដាល សម័យទំនើប ល្ខោន កំណាព្យបទមូលដ្ឋាន បទទ្វេមាត្រ ចម្រៀង រឿងបរទេស និងអត្ថបទទាក់ទងទៅនឹងការវិវឌ្ឍនៃភាសា អក្សរសាស្ត្រ អក្សរសិល្ប៍ ផ្នត់គំនិត ប្រពៃណី ទំនៀមទម្លាប់ ជំនឿ សាសនា ទ្រឹស្តីអក្សរសិល្ប៍ ប្រវត្តិអក្សរសិល្ប៍ លក្ខណៈអក្សរសិល្ប៍។ល។
- សរសេរបំពេញទម្រង់បែបបទនានាក្នុងការសិក្សា កិច្ចការជំនួញ និងជីវភាពសង្គម អាជីព សេវាកម្ម ពាក្យសុំទិដ្ឋាការ លិខិតឆ្លងដែន កិច្ចសន្យា លិខិតមួយចំនួនក្នុងប្រព័ន្ធច្បាប់ និងតុលាការ។
- សរសេរលិខិតមួយចំនួន ក្នុងកិច្ចការរដ្ឋបាលសាធារណៈ ដូចជាកំណត់ហេតុ របាយការណ៍ សំណើផ្សេងៗ ផ្ទេរសិទ្ធិ វិយោគកថា សុន្ទរកថា។ល។
- សរសេរតែងសេចក្តីអត្ថាធិប្បាយពន្យល់ ប្រៀបធៀប ពិភាក្សា។
- តែងកំណាព្យ តែងអត្ថបទផ្សេងៗ និងសំណេរស្រាវជ្រាវដែលមានលក្ខណៈជានិក្ខេបបទ។

### ៣.២- អត្ថបទអក្សរសិល្ប៍

#### ៣.២.១- អក្សរសិល្ប៍ខ្មែរ

រឿងរាមកេរ្តិ៍ខ្មែរ សិលាចារឹក រឿងមួយចំនួនក្នុងទសជាតក(ព្រះវេស្សន្តរតេមិយ ព្រះមហោសថ សុវណ្ណសាម...) រឿងមួយចំនួនក្នុងបញ្ញាសជាតក(រឿងហង្សយន្ត ចៅស្រទបចេក...) រឿងទុំទាវ(ភិក្ខុសោម) រឿងព្រះអាទិត្យថ្មី រះលើផែនដីចាស់(សួន សុរិន្ទ) រឿងភូមិតិរច្ឆាន(ឌឹក គាម និងឌៀក អំ) រឿងគូលីកំណែន(អ៊ឹម ថុក) រឿងគ្រូបង្រៀនស្រុកស្រែ(អ៊ឹម ថុក) រឿងមួយចំនួនក្នុងប្រជុំរឿងព្រេងខ្មែរ រឿងតេជោយ៉ត(ទី ជីហួត) រឿងថៅកែចិត្តចោរ (ពៅ យូឡេង អ៊ុំ ឈឺន) រឿង ជាតិស្ត្រី(ឡឹក វ៉ារី) រឿងល្ខោន និងយីកេខ្មែរមួយចំនួនទៀត។

### ៣.២.២ - អក្សរសិល្ប៍បរទេស

រឿងអ៊ីលីយ៉ាត និងអូឌីសេ (អក្សរសិល្ប៍ក្រិច) រឿងជនកំណាញ់ (អក្សរសិល្ប៍បារាំង) រឿងរាមាយណៈ (អក្សរសិល្ប៍ឥណ្ឌា) រឿងមហាភារតយុទ្ធ(អក្សរសិល្ប៍ឥណ្ឌា) រឿងហាំឡែត (អក្សរសិល្ប៍អង់គ្លេស) រឿងរ៉ូមីអូ និងជូលីយែត (អក្សរសិល្ប៍អង់គ្លេស ) រឿងអាណាចក្របី(អក្សរសិល្ប៍ចិន) រឿងទុរគតជន(វិចទ័រហ៊ុយហ្គោ)និងរឿងមួយចំនួនទៀតរបស់ប្រទេសនានាក្នុងតំបន់ និងលើពិភពលោក។

### ៣.២.៣ - ការសិក្សាអត្ថបទអក្សរសិល្ប៍

ទាំងបណ្តុំវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ត្រូវសិក្សាវិភាគអត្ថបទ៖

- ថ្នាក់ទី១០ : រឿងទុំទាវ និងរឿងតេជោយ៉ត
- ថ្នាក់ទី១១ : រឿងមហាវេស្សន្តរជាតក និងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់
- ថ្នាក់ទី១២ : រឿងរាមកេរ្តិ៍ និងរឿងថៅកែចិត្តចោរ។

## ៣.៣- ប្រធានបទសំខាន់ៗ

### ក- ថ្នាក់ទី១០

មោទនភាពជាតិ អត្តសញ្ញាណជាតិ ការគោរពបូជា សប្បុរសធម៌ សោភណ៍ភាសា ភាតរភាពពិភពលោក ការទទួលស្គាល់ការពិត ភាពជាពលរដ្ឋ ការសម្រេចចិត្ត សោភ័ណសិល្បៈ វប្បធម៌និងសង្គមធម៌ ជំនឿ ភាសា អក្សរ អក្សរសិល្ប៍ សិល្បៈ(ស្ថាបត្យកម្ម ចម្លាក់ ភ្លេង របាំប្រពៃណី) អក្សរសិល្ប៍ប្រជាប្រិយ។ល។

### ខ- ថ្នាក់ទី១១

ផ្ទត់គំនិត ទំនៀមទម្លាប់ សេចក្តីក្លាហាន ការលះបង់ អតីតកាល ការគោរពបូជា តថភាព សុទិដ្ឋិនិយម អក្សរសាស្ត្រ និងអក្សរសិល្ប៍ខ្មែរ អក្សរសិល្ប៍បរទេស ដើមកំណើតជាតិខ្មែរ អក្សរសាស្ត្រនិងអក្សរសិល្ប៍សម័យមុនអង្គរ អក្សរសាស្ត្រ និងអក្សរសិល្ប៍សម័យអង្គរ អក្សរសាស្ត្រនិងអក្សរសិល្ប៍សម័យកណ្តាល អក្សរសាស្ត្រ និងអក្សរសិល្ប៍សម័យបារាំង អក្សរសាស្ត្រ អក្សរសិល្ប៍សម័យបច្ចុប្បន្ន។ល។

### គ- ថ្នាក់ទី១២

អក្សរសិល្ប៍ខេមរនិយម អក្សរសិល្ប៍ព្រាហ្មណ៍និយម អក្សរសិល្ប៍ពុទ្ធនិយម សិល្បៈ ល្ខោន សិលាចារឹក និងរបាំ ប្រពៃណីទំនៀមទម្លាប់ កំណាព្យ ទំនាក់ទំនងរវាងអក្សរសិល្ប៍ខ្មែរនិងបរទេស អក្សរសិល្ប៍បរទេស អក្សរសិល្ប៍ប្រជាប្រិយ របាំប្រពៃណី ទម្រង់នានានៃសិល្បៈ ចម្រៀង តន្ត្រី(ប្រពៃណីនិងសម័យ) ប្រលោមលោក ឥទ្ធិពលសាសនាមកលើអក្សរសាស្ត្រនិងអក្សរសិល្ប៍ខ្មែរ។ល។

## ៣.៤- ខ្លឹមសារសំខាន់ៗ

### ក- សមត្ថភាពស្តាប់

បង្ហាញពីឥរិយាបថវិជ្ជមានក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព យល់ដឹងពីរបៀបស្តាប់ ដើម្បីកំណត់បានខ្លឹមសារ និងរបៀបរកព័ត៌មានសំខាន់ៗ ដើម្បីឆ្លើយនឹងសំណួរទាក់ទងនឹងការស្តាប់អត្ថបទផ្សេងៗ។ ការស្តាប់អត្ថបទអក្សរសិល្ប៍ប្រជាប្រិយរឿងប្រជាប្រិយមាន រឿងបុរាណ រឿងទំនើប និងរឿងល្ខោន។ អត្ថបទកំណាព្យ និងចម្រៀងមានបទមូលដ្ឋាន បទទ្វេមាត្រ និងចម្រៀង។ អត្ថបទផ្សេងៗមាន អត្ថាធិប្បាយ ព័ត៌មាន ការឃោសនា សេចក្តីថ្លែងការណ៍ វិយោគកថា សុន្ទរកថា សង្កកថា អារម្ភកថា បុព្វកថា និងបាឋកថា។

សិស្សមានសមត្ថភាពក្នុងការចងចាំ យល់ន័យ អនុវត្ត វិភាគ វាយតម្លៃ និងបង្កើតថ្មី ដោយឆ្លើយទៅនឹងសំណួរ អ្វី នរណា ឯណា ពេលណា ដូចម្តេច ហេតុអ្វី ក្នុងការរកសេចក្តីលម្អិតបង្ហាញត្រង់និងបង្កប់។ ការប្រើបរិបទដើម្បី

យល់ន័យពាក្យ ពន្យល់ពាក្យ ពហុន័យ បន្ទេរន័យ ទំហៀបន័យ មេតាផរ និងបម្រៀបន័យ...។ ប្រាប់អំពីចំណងជើង ប្រភព ប្រភេទ ចលនា អ្នកនិពន្ធ កាលកំណត់តែង កាលប្រវត្តិ ព្រឹត្តិការណ៍សំខាន់ៗ សង្ខេប ចំណោទបញ្ហា កាលអាកាស ទំនាស់ វិភាគតួអង្គ គំនិតផ្ទាល់ខ្លួននិងអំណះអំណាង តម្លៃអប់រំ ឧត្តមគតិរឿង វិធីតែងនិពន្ធ ផ្ដើមរឿង ដំណើររឿង បញ្ចប់រឿង ។ ញែកភាពខុសគ្នារវាងរឿងប្រជាប្រិយ បុរាណ ទំនើប និងរឿងល្ខោន។ ការបកស្រាយដោយផ្ដល់អំណះអំណាងនិងហេតុផលអំពីការញែករវាង តួអង្គឯក តួអង្គរង តួអង្គបន្ទាប់បន្សំ និងតួអង្គរំព្វក។ ការបកស្រាយអំពីផ្នត់គំនិតអ្នកនិពន្ធ ប្រធានរឿង មូលបញ្ហារឿង និងខ្លឹមសាររឿង។ ស្ដាប់អត្ថបទកំណាព្យបទមូលដ្ឋាន បទទ្វេមាត្រ ដោយផ្ដល់អំពីបញ្ញត្តិ ប្រភេទ លក្ខណៈសម្គាល់ ប្រភព អ្នកនិពន្ធ កាលកំណត់តែង ចំណាប់ជួន ផ្ទួន រណ្ដំ ក្បួនកាព្យមាត្រ ចង្វាក់ សង្គមបរិយាកាស គំនិតសំខាន់ និមិត្តរូប ភាសាច្បាស់លាស់ ភាសារស់រវើក អត្ថន័យ តម្លៃអប់រំ និងការប្រើប្រាស់រូបារម្មណ៍ និងភាពខុសគ្នានៃបទកំណាព្យ។ សង្ខេបគំនិតសំខាន់ លំដាប់គំនិត ប៉ាន់ស្មានខ្លឹមសារ កត់ត្រាចំណុចសំខាន់ៗ សន្និដ្ឋាន អត្ថន័យ តម្លៃអប់រំ រៀបព្រឹត្តិការណ៍ដែលមានលក្ខណៈស្មុគស្មាញតាមលំដាប់កាលបរិច្ឆេទ។ វាយតម្លៃគំនិត ព័ត៌មាន ហេតុការណ៍ រឿងរ៉ាវព្រឹត្តិការណ៍ ឬការឃោសនា ភាពលម្អៀង បុរេនិច្ឆ័យ និងវិធីអូសទាញឬបញ្ចុះបញ្ចូលរបស់អ្នកនិពន្ធ។

**ខ- សមត្ថភាពនិយាយ**

បង្ហាញឥរិយាបថក្នុងការនិយាយប្រកបដោយប្រសិទ្ធភាព យល់ដឹងពីរបៀបនិយាយ ដោយចេះលើកដាក់សំឡេង សម្ដែងកាយវិការ និងទឹកមុខបានសមស្របទៅតាមប្រធានបទនីមួយៗមាន ការពង្រីកគំនិតដើម្បីផ្ដល់សេចក្ដីពន្យល់ ការការពារប្រធានបទដែលបានបង្ហាញ ការឃោសនា ការធ្វើបទសម្ភាស ការចរចានិងសម្របសម្រួល ការធ្វើអត្ថាធិប្បាយ ការថ្លែងសុន្ទរកថា បាឋកថា ការធ្វើវាគ្មិនក្នុងវេទិកាផ្សេងៗ ការធ្វើបទបង្ហាញ ការបញ្ចេញទស្សនៈលើប្រធានបទនិងព័ត៌មាន និងការសម្របសម្រួល វែកញែក ពិភាក្សាបញ្ចេញយោបល់ ត្រិះរិះពិចារណា រកហេតុផលសំយោគ វាយតម្លៃ និងដោះស្រាយបញ្ហាប្រកបដោយ ប្រសិទ្ធភាពខ្ពស់ ។

**គ- សមត្ថភាពអាន**

បង្ហាញពីឥរិយាបថវិជ្ជមានក្នុងការអានប្រកបដោយប្រសិទ្ធភាព ចេះលើកដាក់សំឡេង ចេះគោរពសញ្ញាសម្ព័ន្ធ មានទឹកមុខ កាយវិការសមរម្យ យល់ដឹងពីរបៀបអានដើម្បីកំណត់បានពី ខ្លឹមសារ និងរបៀបរកព័ត៌មាន។ ការអានអត្ថបទរឿងដកស្រង់ពីអក្សរសិល្ប៍ខ្មែរនិងបរទេសមានរឿងប្រជាប្រិយ រឿងបុរាណ រឿងទំនើប។ ទ្រឹស្ដីអក្សរសិល្ប៍មានចលនាអក្សរសិល្ប៍មាន ព្រាហ្មណ៍និយម ពុទ្ធនិយម ខេមរនិយម បរទេសនិយម និងលក្ខណៈអក្សរសិល្ប៍មាន លក្ខណៈជាតិ លក្ខណៈសង្គម លក្ខណៈប្រវត្តិ លក្ខណៈអន្តរជាតិ លក្ខណៈវណ្ណៈ លក្ខណៈតថៈលក្ខណៈបក្ស និងលក្ខណៈប្រជាជន។ ការសិក្សាអត្ថបទអក្សរសិល្ប៍រឿងរាមកេរ្តិ៍ និងរឿងថៅកែចិត្តចោរ។ កំណាព្យនិងចម្រៀងមានកំណាព្យបទមូលដ្ឋាន បទទ្វេមាត្រ និងចម្រៀងមានចម្រៀងប្រជាប្រិយចម្រៀង និងប្រពៃណី។ ការអានអត្ថបទដែលមានទម្រង់ខុសគ្នាមាន អត្ថបទអត្ថាធិប្បាយ ព័ត៌មាន ការឃោសនា វិយោគកថា សុន្ទរកថា សង្កកថា សេចក្ដីថ្លែងការណ៍ អារម្ភកថា បុព្វកថា បទវិចារណកថា វិភាគកថា និងបាឋកថា។ អត្ថបទស្រាវជ្រាវ និងការប្រើប្រាស់ឯកសារយោងដូចជា វប្បធម៌អរិយធម៌ខ្មែរ វប្បធម៌អរិយធម៌បរទេស និងឥទិ្ធពលវប្បធម៌បរទេសនៅក្នុងសង្គមខ្មែរ ព្រមទាំងអត្ថបទដែលបានស្រាវជ្រាវរកឃើញ និងការប្រើប្រាស់ឯកសារយោង។

សិស្សយល់ដឹងពីរបៀបអាន របៀបរកព័ត៌មាន និងមានសមត្ថភាពក្នុងការចងចាំ យល់ន័យ អនុវត្ត វិភាគ វាយតម្លៃ និងបង្កើតថ្មី ឧបបទ មេតាផរ បំរៀបន័យ បន្ទេរន័យ និងទំហៀបន័យ។ ការបកស្រាយអំពីចំណងជើង ប្រភព ប្រភេទ ចលនា អ្នកនិពន្ធ កាលកំណត់តែង កាលប្រវត្តិ ព្រឹត្តិការណ៍សំខាន់ៗ សង្ខេប តួអង្គឯក តួអង្គរង តួអង្គបន្ទាប់បន្សំ តួអង្គរំព្វក កាលអាកាស ប្រធានរឿង មូលបញ្ហា ទំនាស់ វិភាគតួអង្គ ឧត្តមគតិរឿង វិធីតែងនិពន្ធ ផ្ដើម

រឿង ដំណើររឿង បញ្ចប់រឿង កុសលរស សង្គមរស តថរស វីររស អច្ឆរិយរស ហាសរស ទារុណរស នាដរស នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ សន្និដ្ឋាន គំនិតបង្កើតថ្មីដើម្បីច្នៃប្រឌិតរឿង និងភាពខុសគ្នានៃរឿង។ ការបកស្រាយអំពីចលនាអក្សរសិល្ប៍ និងលក្ខណៈអក្សរសិល្ប៍។ ការសិក្សាអត្ថបទអក្សរសិល្ប៍រឿងមហាវេស្សន្តរជាតក និងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់។ ការបកស្រាយអំពីប្រភេទ លក្ខណៈសម្គាល់ ប្រភព អ្នកនិពន្ធ កាលកំណត់តែង សញ្ញាពិសេសនៃកំណាព្យ ចំណាប់ជួន ផ្ទួន រណ្ដំ ក្បួនកាព្យមាត្រ គំនិតសំខាន់ ភាសាច្បាស់លាស់ ភាសារស់រវើក អត្ថន័យតម្លៃអប់រំ ចង្វាក់ របៀបស្នូត និងបរិយាកាស កាព្យរូបារម្មណ៍មាន បំរៀបន័យរូបារម្មណ៍ រូបារូប្បារម្មណ៍ និងភាពខុសគ្នានៃកំណាព្យ។ ចម្រៀងចម្រៀងប្រជាប្រិយ ប្រពៃណី និងសម័យតាមបែបបទ។ ការបកស្រាយអំពីការវាយតម្លៃគំនិតព័ត៌មាន ហេតុការណ៍ រឿងរ៉ាវ ព្រឹត្តិការណ៍ ឬការឃោសនា) គំនិតអូសទាញ ភាពលម្អៀង និងបុរេនិច្ឆ័យ និយមន័យវប្បធម៌អរិយធម៌និងសង្គមធម៌ ប្រវត្តិនៃផ្នត់គំនិត ជំនឿ ប្រពៃណីទំនៀមទម្លាប់របស់ខ្មែរ និងមេកធាងរបស់អរិយធម៌នៃវប្បធម៌អរិយធម៌និងសង្គមធម៌ខ្មែរ និងបរទេស ឥទ្ធិពលវប្បធម៌បរទេសនៅក្នុងសង្គមខ្មែរ ការប្រើប្រាស់ឯកសារយោង និងស្នាដៃដែលបានស្រាវជ្រាវរកឃើញ។

**ឃ- សមត្ថភាពសរសេរ**

ការយល់ដឹងពីសំនួនពាក្យ ន័យ និងទម្រង់បែបបទនៃសំណេរផ្សេងៗដូចជា ការបំពេញទម្រង់បែបបទ ការសរសេរលិខិតឯកជន លិខិតរដ្ឋបាល កំណត់ហេតុ និងរបាយការណ៍។ សំណេរអត្ថបទដែលមានទម្រង់ខុសៗគ្នាមានដូចជា អត្ថបទអត្ថាធិប្បាយ ព័ត៌មាន ការឃោសនា វិយោគកថា សុន្ទរកថា សង្កកថា សេចក្ដីថ្លែងការណ៍ អារម្ភកថា បុព្វកថា បទវិចារណកថា វិភាគកថា បាឋកថា។ តែងកំណាព្យនិងចម្រៀងមាន កំណាព្យបទមូលដ្ឋាន បទទ្វេមាត្រ និងចម្រៀង។ សំណេរតែងសេចក្ដី សំណេរស្រាវជ្រាវចងក្រង ការធ្វើផែនការ ការប្រើលេខរៀង យោង និងឧបសម្ព័ន្ធ។ ការបកស្រាយទិន្នន័យតាមការវិភាគ ការធ្វើផែនការ ការធ្វើគម្រោង ការចងក្រងរឿងនិទាននិងរឿងល្ខោន ការចងក្រងប្រវត្តិទីកន្លែងសំខាន់ៗ និងសំណេរវិភាគនិងតាក់តែងអត្ថបទ

សិស្សមានសមត្ថភាពក្នុងការបំពេញទម្រង់បែបបទ តាក់តែងអត្ថបទ និងសរសេរបកស្រាយអំពីប្រធានបទផ្សេងៗដូចជា ពាក្យសុំចុះឈ្មោះប្រឡង ពាក្យសុំចូលបម្រើការងារ ពាក្យស្នើសុំអាហារូបករណ៍ និងពាក្យសុំប្រកបអាជីវកម្ម លិខិតថ្កោលទោស ពាក្យដាក់ដេញថ្លៃ លិខិតសូមអភ័យទោស លិខិតសរសើរ លិខិតលាលែង លិខិតបញ្ជាបេសកកម្ម ឧទ្ទេសនាម លិខិតតែងតាំង កំណត់ហេតុ របាយការណ៍។ តែងអត្ថបទដែលមានទម្រង់ខុសៗគ្នាដូចជា អារម្ភកថា បុព្វកថា និងបទវិចារណកថា វិភាគកថា និងបាឋកថា។ តែងកំណាព្យ និងចម្រៀង បទមូលដ្ឋាន បទទ្វេមាត្រ និងចម្រៀង។ តែងសេចក្ដី មាន សំណេរសំយោគ សំណេរប្រៀបធៀប សំណេរបញ្ចុះបញ្ចូល តែងសេចក្ដីបែបអត្ថាធិប្បាយពន្យល់ប្រៀបធៀប និងពិភាក្សា។ សំណេរការបកស្រាយទិន្នន័យតាមការវិភាគ ផែនការ គម្រោង ការចងក្រងរឿងនិទាន រឿងល្ខោន ប្រវត្តិទីកន្លែងសំខាន់ៗ ការវិភាគនិងការតាក់តែងអត្ថបទ និងសំណេរស្រាវជ្រាវបែបនិក្ខេបបទ។

**ង- វេយ្យាករណ៍**

សិក្សានិងការប្រើប្រាស់ប្រភេទនៃនាមនិងមុខងារនៃសាធារណនាមឬនាមសាធារណ៍ អសាធារណនាមឬនាមអសាធារណ៍ ករណនាមឬនាមករណ៍ និងការកនាមឬនាមការក៍។ ប្រភេទនៃសព្វនាមនិងមុខងារនៃសព្វនាមបុរិសៈ សព្វនាមចង្អុល សព្វនាមសំណួរ សព្វនាមឈ្នាប់ និងសព្វនាមមិនច្បាស់។ ប្រភេទនៃគុណនាមនិងមុខងារនៃគុណនាមប្រក្រតី គុណនាមកំណត់(កម្មសិទ្ធិ សំណួរ ចំនួន ចង្អុល និងមិនច្បាស់)។ ប្រភេទនៃកិរិយាសព្ទនិងមុខងារ នៃកិរិយាសុទ្ធ កិរិយាហេតុកិរិយាសកម្ម និងករិយាអកម្ម។ ប្រភេទនៃគុណកិរិយា និងមុខងារនៃ គុណករិយាកន្លែង គុណកិរិយាកាលគុណករិយាបរិមាណ គុណកិរិយាសំណួរ និងគុណកិរិយាបំណែប។ ចំណងធ្នាក់និងឈ្នាប់

និងមុខងារ។ ប្រភេទនៃជំនួយកិរិយា និងមុខងារនៃប្រាប់លទ្ធផល ប្រាប់ទិសដៅ ប្រាប់កាល និងប្រាប់ទិដ្ឋភាព។ សិស្សយល់ដឹងពីសារៈសំខាន់ សារប្រយោជន៍ និងការប្រើប្រាស់ល្បះទោល ល្បះផ្សំ ល្បះក្រុង និងសញ្ញាកត់សូរអន្តរជាតិ(API) កម្លាយ ការបន្លឺសំឡេង សូរស្រៈ សញ្ញាស្រៈខ្មែរ ព្យញ្ជនៈទោល សូរព្យញ្ជនៈ ព្យញ្ជនៈផ្សំ ព្យាង្គ និងសទ្ទក្នុងព្យាង្គ។បញ្ជិកានៃភាសា អំពីពាក្យ ការបន្លឺសំឡេង សូរស្រៈ សញ្ញាស្រៈខ្មែរ ព្យញ្ជនៈទោល សូរព្យញ្ជនៈ ព្យញ្ជនៈផ្សំ ព្យាង្គ និងសទ្ទក្នុងព្យាង្គ។

## ៤- របាយម៉ោងសិក្សា

ក្នុង១ឆ្នាំសិក្សា ត្រូវសិក្សា៣៥ សប្តាហ៍ ។សិក្សា៦ថ្ងៃក្នុង១សប្តាហ៍។ សិក្សាពី៤ទៅ៧ម៉ោងសិក្សាក្នុង១ថ្ងៃ។ ១ម៉ោងសិក្សា មានរយៈពេល ៥០នាទី។

របាយម៉ោងសិក្សាអក្សរសាស្ត្រខ្មែរ សម្រាប់មធ្យមសិក្សាទុតិយភូមិ បានបែងចែកដូចក្នុងតារាងខាងក្រោម៖

| ថ្នាក់ | បណ្តុំវិទ្យាសាស្ត្រសង្គម | បណ្តុំវិទ្យាសាស្ត្រ |
|---|---|---|
| ១០ | ៦ម៉ោង x៣៥ សប្តាហ៍ = ២១០ម៉ោង/១ឆ្នាំសិក្សា | ៥ម៉ោង x៣៥ សប្តាហ៍ = ១៧៥ម៉ោង/១ឆ្នាំសិក្សា |
| ១១ | ៦ម៉ោង x៣៥ សប្តាហ៍ = ២១០ម៉ោង/១ឆ្នាំសិក្សា | ៥ម៉ោង x៣៥សប្តាហ៍ = ១៧៥ម៉ោង/១ឆ្នាំសិក្សា |
| ១២ | ៦ម៉ោង x៣៥ សប្តាហ៍ = ២១០ម៉ោង/១ឆ្នាំសិក្សា | ៥ម៉ោង x៣៥សប្តាហ៍ = ១៧៥ម៉ោង/១ឆ្នាំសិក្សា |

**សមាសភាគនិងភាគរយម៉ោងសិក្សាមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១០-១២**

ម៉ោងសិក្សានៅតាមសមាសភាគនានានៃមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ត្រូវបានបែងចែកដូចខាងក្រោម៖




ម៉ោងសិក្សាទៅតាមសមាសភាគនីមួយៗ នៃមុខវិជ្ជាអក្សរសាស្ត្រខ្មែរ នៅមធ្យមសិក្សាទុតិយភូមិ ៖

| សមាសភាគ | បណ្តុំវិទ្យាសាស្ត្រសង្គម (២១០ម៉) | បណ្តុំវិទ្យាសាស្ត្រ(១៧៥ម៉) |
|---|---|---|
| ការស្តាប់ | ១០ ភាគរយ = ២១ ម៉ោង | ១០ ភាគរយ = ១៧ ម៉ោង |
| ការនិយាយ | ១០ ភាគរយ = ២១ ម៉ោង | ១០ ភាគរយ = ១៧ ម៉ោង |
| ការអាន | ៣៥ ភាគរយ = ៧៣.៥០ ម៉ោង | ៣៥ ភាគរយ = ៦២ ម៉ោង |
| ការសរសេរ | ៣៥ ភាគរយ = ៧៣.៥០ ម៉ោង | ៣៥ ភាគរយ = ៦២ ម៉ោង |
| វេយ្យាករណ៍ | ១០ ភាគរយ = ២១ ម៉ោង | ១០ ភាគរយ = ១៧ ម៉ោង |
| **សរុប** | **១០០ ភាគរយ = ២១០ ម៉ោង** | **១០០ ភាគរយ = ១៧៥ ម៉ោង** |

***កំណត់សម្គាល់ ៖*** *ការកំណត់ចំនួនម៉ោងតាមភាគរយនៃសមាសភាគនីមួយៗ ត្រូវបានបង្គត់ខ្លះដើម្បីងាយស្រួលក្នុងការបែងចែក ។*

## ៥- ការណែនាំអនុវត្ត

### ៥.១- ការអនុវត្តកម្មវិធីសិក្សាអក្សរសាស្ត្រខ្មែរ

ការកែទម្រង់កម្មវិធីសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រ ជាផ្នែកមួយក្នុង កំណែទម្រង់កម្មវិធីសិក្សានៃកម្មវិធីកំណែទម្រង់វិស័យអប់រំ ពោលគឺធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត។ ការកែទម្រង់កម្មវិធីសិក្សាភាសាខ្មែរ ធ្វើឡើងដោយផ្អែកតាមក្របខណ្ឌកម្មវិធីសិក្សា ដែលផ្ដោតចំណុចសំខាន់ៗដូចជា ប្រធានបទ លទ្ធផលសិក្សា ខ្លឹមសារ គន្លឹះសំខាន់ៗ វិធីសាស្ត្របង្រៀន របាយម៉ោង ការវាយតម្លៃ ការពិនិត្យតាមដាន សៀវភៅសិក្សាគោល និងសម្ភារៈសិក្សា។ កម្មវិធីសិក្សាលម្អិតនេះ មានបួនសមត្ថភាពគឺ ស្ដាប់ និយាយ អាន និងសរសេរ។ នៅក្នុងសមត្ថភាពនីមួយៗ បានកំណត់នូវលទ្ធផលសិក្សាទៅតាមកម្រិតថ្នាក់។ ដូច្នេះដើម្បីអនុវត្តកម្មវិធីសិក្សាឱ្យមានប្រសិទ្ធភាពត្រូវ៖

- ការអនុវត្តម៉ោងសិក្សា: របាយម៉ោងកម្មវិធីសិក្សា អនុវត្តតាមម៉ោងកំណត់ក្នុងក្របខណ្ឌកម្មវិធីសិក្សា។ ម៉ោងសិក្សា ត្រូវបានបែងចែកទៅតាមសមាសភាគ ស្ដាប់ និយាយ អាន សរសេរ និងវេយ្យាករណ៍។ ការអនុវត្តម៉ោងសិក្សា ត្រូវមានភាពទន់ភ្លន់ និងត្រឹមត្រូវច្បាស់លាស់ ទើបមានប្រសិទ្ធភាព។
- ការវាយតម្លៃ : ការវាយតម្លៃត្រូវធ្វើជាប្រចាំ អាស្រ័យនឹងពេលវេលា និងប្រភេទតេស្តនីមួយៗ។ រាល់ការធ្វើតេស្តត្រូវមានឧបករណ៍សម្រាប់វាយតម្លៃជាការចាំបាច់។ ឧបករណ៍តេស្ត គួររៀបចំជារួមទៅតាម ខណ្ឌ ក្រុង ស្រុក រាជធានី ខេត្ត និងអាចប្រើឧបករណ៍ថ្នាក់ជាតិ។ ការវាយតម្លៃមានច្រើនរូបភាពគឺ ការសង្កេត ការសម្ភាស ការពិនិត្យតាមដាន និងការធ្វើតេស្ត។ ការធ្វើតេស្ត មានច្រើនរូបភាពដូចជា បុរេតេស្ត តេស្តតាមដំណាក់ (តេស្តវាយតម្លៃដំណើរការរៀននិងបង្រៀន និងតេស្តវាយតម្លៃសមត្ថភាពសិស្ស) តេស្តបញ្ចប់ តេស្តប្រចាំខែ តេស្តប្រចាំឆមាស តេស្តថ្នាក់ជាតិ និងការប្រឡងថ្នាក់ជាតិ។ ចំពោះតេស្តប្រចាំខែនិងឆមាស គួរធ្វើឡើងដោយមានឧបករណ៍តេស្តរួមគ្នាទៅតាមកម្រង ខណ្ឌ ក្រុង ស្រុក រាជធានីខេត្ត និងអាចប្រើឧបករណ៍ថ្នាក់ជាតិ។
- សម្ភារៈឧបទេស : សម្ភារៈឧបទេស គឺជាសមាសភាគចាំបាច់មួយ សម្រាប់ជួយឱ្យការរៀននិងបង្រៀនមានប្រសិទ្ធភាព។ ការប្រើប្រាស់សម្ភារៈឧបទេស ត្រូវធានាថាបានប្រើប្រាស់ទាំងគ្រូទាំងសិស្ស។ សម្ភារឧបទេសមានដូចជា សម្ភារៈជាក់ស្ដែង សម្ភារៈច្នៃប្រឌិត ករណីសិក្សា ឯកសារផ្សេងៗ សម្ភារៈអេឡិចត្រូនិចអ៊ិនធើណែត និងប្រព័ន្ធបណ្ដាញសង្គមជាដើម។
- ឯកសារជំនួយ : ការប្រើប្រាស់សៀវភៅសិក្សាគោលតែមួយមុខ មិនគ្រប់គ្រាន់សម្រាប់ការអនុវត្តកម្មវិធីសិក្សាឱ្យបានល្អនោះទេ។ ការផលិតនិងប្រើប្រាស់ឯកសារជំនួយ គឺមានសារៈសំខាន់ណាស់សម្រាប់ជួយដល់ដំណើរការរៀននិងបង្រៀន។ ឯកសារជំនួយមានដូចជា អំណានបន្ថែម សម្ភារៈសិក្សា វចនានុក្រម គរុកោសល្យ វិធីសាស្ត្របង្រៀន លំហាត់កិច្ចការ ខ្លឹមសារគន្លឹះ ឧបករណ៍វាយតម្លៃ និងឯកសារយោងផ្សេងៗជាដើម។
- ការយល់ដឹងពីកម្មវិធីសិក្សា : សមាសភាគសំខាន់ៗមាន លទ្ធផលសិក្សា(វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា) វិធីសាស្ត្របង្រៀន របាយម៉ោងសិក្សា សម្ភារឧបទេស ឯកសារជំនួយ ការណែនាំអនុវត្ត ប្រធានបទ ការវាយតម្លៃ និងឯកសារជំនួយ។ ដើម្បីអនុវត្តកម្មវិធីសិក្សាមានប្រសិទ្ធភាព គ្រូបង្រៀននិងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវយល់ដឹងពីកម្មវិធីសិក្សា និងចេះប្រើប្រាស់កម្មវិធីសិក្សា ព្រមទាំងដាក់បញ្ចូលលទ្ធផលសិក្សាទៅក្នុងកិច្ចតែងការបង្រៀន និងបំណែងចែកកម្មវិធីបង្រៀនប្រចាំខែ។
- ការផ្សារភ្ជាប់ទៅនឹងជីវភាពជាក់ស្ដែង : ការរៀននិងបង្រៀនអក្សរសាស្ត្រខ្មែរ ត្រូវផ្សារភ្ជាប់ជាមួយនឹងជីវភាពជាក់ស្ដែង។ ក្នុងការរៀននិងបង្រៀន ធ្វើយ៉ាងណាឱ្យសិស្សទទួលបាននូវចំណេះដឹងនិងបំណិនឬជំនាញ។ សិស្សត្រូវយល់ដឹងពីសារៈសំខាន់និងសារប្រយោជន៍នៃចំណេះដឹងនិងបំណិនឬជំនាញទាំងនោះ ហើយចេះ

យកចំណេះដឹងនិងបំណិនឬជំនាញទាំងនោះទៅប្រើប្រាស់ឬអនុវត្ត សំដៅធ្វើឱ្យទទួលបាននូវគុណតម្លៃ ដែលកើតឡើងពីការសិក្សាភាសានិងអក្សរសាស្ត្រខ្មែរគ្រប់កម្រិត។

### ៥.២- ការអភិវឌ្ឍសៀវភៅសិក្សាគោល

ដើម្បីអនុវត្តកម្មវិធីសិក្សាអក្សរសាស្ត្រខ្មែរ នៅមធ្យមសិក្សាទុតិយភូមិថ្នាក់ទី១០ ទី១១ និងទី១២ ប្រកបដោយគុណភាព និងប្រសិទ្ធភាពនោះ អ្នកពាក់ព័ន្ធគប្បីធ្វើឱ្យសម្រេចនូវចំណុចសំខាន់ៗដូចខាងក្រោម៖

- សៀវភៅសិក្សាគោល : ការតាក់តែងសៀវភៅសិក្សាគោល ត្រូវមានទាំងសៀវភៅសម្រាប់សិស្ស និងសៀវភៅសម្រាប់គ្រូ។ សៀវភៅសិក្សាគោល ត្រូវរៀបចំឱ្យមានភាពគ្របដណ្តប់ខ្លឹមសាររបស់កម្មវិធីសិក្សា និងមានចង្អុលបង្ហាញពី ខ្លឹមសារគន្លឹះសំខាន់ៗ វិធីសាស្ត្រ ម៉ោងសិក្សា សម្ភារៈឧទេស ការវាយតម្លៃ និងផ្សារភ្ជាប់ទៅនឹងជីវភាពជាក់ស្តែង។ ការរៀបចំសៀវភៅសិក្សាគោល ត្រូវធានាថា សិស្សគ្រប់តំបន់ ជនជាតិ ជនពិការ អាចយកមកច្នៃប្រឌិតអនុវត្តបានទាំងអស់គ្នា។
- សៀវភៅសិក្សាគោល គប្បីអភិវឌ្ឍទៅតាមបណ្តុំមុខវិជ្ជា គឺបណ្តុំវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម មានសៀវភៅសម្រាប់សិស្ស និងសម្រាប់គ្រូ ដោយអភិវឌ្ឍទៅតាមបំណែងចែកម៉ោងសិក្សា និងបំណែងចែកសមាសភាគលទ្ធផលសិក្សា ទៅតាមបណ្តុំមុខវិជ្ជាសិក្សា។ ចំណែកឯកសារជំនួយ និងសម្ភារៈឧបទេសដទៃទៀត ក៏ត្រូវបានអភិវឌ្ឍ ដើម្បីជួយពង្រឹងការរៀន និងបង្រៀនប្រកបដោយគុណភាព និងប្រសិទ្ធភាព។

### ៥.៣- វិធីសាស្ត្របង្រៀន

- វិធីសាស្ត្របង្រៀន ការរៀននិងបង្រៀនអក្សរសាស្ត្រខ្មែរ ធ្វើយ៉ាងណាឱ្យសិស្សយល់ដឹងពីរបៀបរៀនដោយខ្លួនឯង ពោលគឺមិនត្រូវឱ្យសិស្សរៀនបានត្រឹមតែគ្រាប់តាមនោះទេ។ គ្រូគប្បីប្រើប្រាស់វិធីសាស្ត្របង្រៀនសម្បូរបែបស្របតាមកាលៈទេសៈ និងស្ថានភាពជាក់ស្តែង ជាពិសេសវិធីសាស្ត្របង្រៀនថ្មីៗមាន វិធីសាស្ត្របែបស្រាវជ្រាវ បែបសហការ និងបែបបិះរកជាដើម។ ការបង្រៀនត្រូវរកឱ្យឃើញចំណុចគន្លឹះ ដែលអាចធ្វើឱ្យសិស្សយល់ដឹងច្បាស់លាស់។ដូចជាចំណុចគន្លឹះក្នុងការបង្រៀនវេយ្យាករណ៍ បំណិន អក្សរសិល្ប៍ជាដើមត្រូវឱ្យសិស្សចេះបកស្រាយបញ្ញត្តិ ចេះវិភាគនិងចេះប្រើប្រាស់។ការរៀននិងបង្រៀនអក្សរសាស្ត្រខ្មែរ ត្រូវប្រើប្រាស់សំណួរទាំង៦កម្រិតគឺ ចងចាំ យល់ដឹង អនុវត្ត វិភាគ វាយតម្លៃ និងបង្កើតថ្មី។
- ការរៀននិងបង្រៀនអក្សរសាស្ត្រខ្មែរ ធ្វើយ៉ាងណាឱ្យសិស្សយល់ដឹងពីរបៀបរៀនដោយខ្លួនឯង ពោលគឺមិនត្រូវឱ្យសិស្សរៀនបានត្រឹមតែគ្រាប់តាមនោះទេ។ គ្រូគប្បីប្រើប្រាស់វិធីសាស្ត្របង្រៀនសម្បូរបែប ស្របតាមកាលៈទេសៈនិងស្ថានភាពជាក់ស្តែង ជាពិសេសវិធីសាស្ត្របង្រៀនថ្មីៗមាន វិធីសាស្ត្របែបស្រាវជ្រាវ បែបសហការ និងបែបបិះរកជាដើម។
- រៀបចំសកម្មភាពការរៀននិងបង្រៀន ដោយមានភាពទន់ភ្លន់ និងច្នៃប្រឌិតធ្វើយ៉ាងណា ឱ្យសម្រេចតាមវត្ថុបំណងមេរៀនដែលបានគ្រោងទុក។
- នាំសិស្សឱ្យស្គាល់ពីគោលបំណងនិងតម្លៃនៃសមត្ថភាពស្តាប់និយាយ អាន និងសរសេរឱ្យបានច្បាស់លាស់។
- រៀបចំសិស្សឱ្យមានសកម្មភាពច្រើន ក្នុងការសិក្សា ដូចជាសកម្មភាពក្រុម ការងារដៃគូ ជាបុគ្គល ល្បែងដើរតួ ពិភាក្សា សម្របសម្រួល និងស្រាវជ្រាវជាដើម។
- ជំរុញសិស្សឱ្យមានភាពក្លាហាន ចូលរួមសិក្សាក្នុងការបញ្ចេញមតិ យោបល់ គាំទ្រ ជំទាស់បង្ហាញហេតុផល ហ៊ានសួរ ឆ្លើយ ហ៊ានទទួលខុស ត្រូវស្ថិតក្នុងក្របខណ្ឌវិន័យ និងច្បាប់។
- ជំរុញនិងលើកទឹកចិត្តសិស្ស ឱ្យចូលចិត្តអាននិងស្រាវជ្រាវឯកសារនានា ដែលមានប្រយោជន៍ សម្រាប់ការសិក្សា ដូចជាអត្ថបទព័ត៌មាន អត្ថបទអក្សរសិល្ប៍ខ្មែរ និងបរទេស។

- ជំរុញនិងលើកទឹកចិត្តសិស្ស ឱ្យចូលចិត្តតាក់តែងស្នាដៃ ដែលបម្រើឱ្យការសិក្សា និងការរស់នៅប្រចាំថ្ងៃ ដូចជា
- សំណេរតែងសេចក្តី តាក់តែងកំណាព្យ រឿងផ្សេងៗ លិខិតរដ្ឋបាលមួយចំនួនដូចជារបាយការណ៍ កំណត់ហេតុ សុន្ទរកថា។ល។
- បណ្តុះទម្លាប់សិស្សឱ្យចេះរៀនដោយខ្លួនឯង រៀនជាក្រុម រៀនក្នុងក្លឹបសិក្សាក្នុងបណ្ណាល័យស្រាវជ្រាវ។ល។
- បង្ហាញពីគុណតម្លៃ និងសម្រួចទេពកោសល្យរបស់សិស្ស ទៅតាមជំនាញរបស់សិស្ស ក្នុងការសិក្សាទៅតាមបណ្តុំមុខវិជ្ជាសិក្សា(វិទ្យាសាស្ត្រ ឬវិទ្យាសាស្ត្រសង្គម )។

### ៥.៤- ការប្រើប្រាស់សម្ភារៈឧបទេសនិងសម្ភារៈដំណើរការរៀននិងបង្រៀន

សម្ភារៈឧបទេស គឺជាធនធានទាំងឡាយណាដែលគ្រូនិងសិស្សយកមកប្រើប្រាស់ក្នុងការរៀននិងបង្រៀន។ សម្ភារៈឧបទេសនិងសម្ភារៈជំនួយ ជាមធ្យោបាយនិងជាលក្ខខណ្ឌចាំបាច់ សម្រាប់ ប្រើប្រាស់ក្នុងដំណើរការរៀននិងបង្រៀន ប្រកបដោយប្រសិទ្ធភាព ដើម្បីឱ្យខ្លឹមសារមេរៀនកាន់តែច្បាស់លាស់ ងាយយល់ ងាយចាប់បាន ហើយអាចសម្រេច វត្ថុបំណងមេបានល្អប្រសើរ។ ការបង្រៀន ដែលប្រើប្រាស់សម្ភារៈឧបទេស គឺជាការជួយពង្រឹងដល់ការសិក្សារបស់សិស្ស ឱ្យកាន់តែយល់ច្បាស់នូវន័យរបស់ពាក្យគន្លឹះ កន្សោមពាក្យ ខ្លឹមសារអត្ថបទពិសេសផ្នែកវេយ្យាករណ៍។ លោកគ្រូ អ្នកគ្រូ គប្បីឱ្យសិស្ស ហាត់ប្រើសម្ភារៈដោយខ្លួនឯង ចុះស្រាវជ្រាវ សង្កេតដោយផ្ទាល់ដល់ទីកន្លែង ដើម្បីឱ្យសិស្សកាន់តែយល់ច្បាស់ខ្លឹមសារមេរៀនដែលបានបង្រៀនរួច។កត្តាសំខាន់គ្រូបង្រៀនត្រូវកំណត់សម្ភារៈបង្រៀនឱ្យបានច្បាស់លាស់ទៅតាមតម្រូវការនៃមេរៀននីមួយៗ។ សម្ភារៈឧបទេស ដែលគ្រូបង្រៀនត្រូវប្រើប្រាស់ សម្រាប់ដំណើរការរៀននិងបង្រៀន គឺជាសម្ភារៈទាំងឡាយណាដែលងាយរក ងាយផលិត ងាយសង្កេត និងប្រើប្រាស់ ហើយមានគុណភាព និងមានប្រសិទ្ធភាព។

#### ក- សម្ភារៈរូបី

កម្មវិធីសិក្សាលម្អិតចំណេះទូទៅ សម្រាប់មធ្យមសិក្សាទុតិយភូមិ ទាមទារឱ្យគ្រូបង្រៀនចេះប្រើប្រាស់វត្ថុពិត ជាក់ស្តែង រុក្ខជាតិ សត្វ ធម្មជាតិ វត្ថុសិល្បៈ ទីកន្លែង បេតិកភណ្ឌ សម្ភារៈប្រពៃណី ទស្សនីយភាពពិត ដូចជាចម្រៀង វីដេអូជាដើម ដោយគ្រូចេះដឹកនាំសិស្សចុះសិក្សា សង្កេត ស្រាវជ្រាវ វិភាគ ពន្យល់ បង្ហាញជាក់ស្តែង ដើម្បីបង្កើនការយល់ដឹងអំពីបញ្ញត្តិ ខ្លឹមសារ មេរៀនទាក់ទងនឹងប្រធានបទ។ សម្ភារៈរូបីសម្រាប់មធ្យមសិក្សាទុតិយភូមិ គឺសំដៅលើប្រភេទសម្ភារៈដូចជា កែវ ថូ គ្រឿងអលង្ការ សម្ភារៈប្រើប្រាស់បុរាណ ចម្លាក់ សិលាចារឹក ទីកន្លែងជាក់ស្តែង។ល។

#### ខ- សម្ភារៈពាក់កណ្តាលរូបី

សម្ភារៈរូបីឬលក្ខណៈជាក់ស្តែង មិនអាចឆ្លើយតបទៅនឹងស្ថានភាពនៃការសិក្សា តាមតំបន់នានាបានឡើយ គឺទាមទារឱ្យគ្រូបង្រៀនចេះផលិត និងប្រើប្រាស់សម្ភារៈពាក់កណ្តាលរូបី។ សម្ភារៈពាក់កណ្តាលរូបី សំដៅលើប្រភេទសម្ភារៈមួយចំនួន ដែលផលិតតំណាងពីរូបពិត វត្ថុពិត ឬទីកន្លែងពិត។ សម្ភារៈទាំងនេះមានដូចជា រូបថត ឬរូបភាពមនុស្ស សត្វ វត្ថុ រុក្ខជាតិ ធម្មជាតិ ទីកន្លែង ដែលគ្រូផលិត ឡើងសម្រាប់ជាជំនួយក្នុងការរៀន និងបង្រៀន។

#### គ- សម្ភារៈអរូបី

សម្ភារៈអរូបី គឺសម្ភារៈដែលមិនមែនជាក់ស្តែង និងមិនមែនជារូបថតឬរូបភាពសម្គាល់ច្បាស់លាស់នោះទេ វាគ្រាន់តែត្រូវគេលើកមកជាតំណាង សន្មតឬជាគ្រឿងសម្គាល់ឈ្មោះមនុស្ស សត្វ វត្ថុ រុក្ខជាតិ ទីកន្លែង...។ សម្ភារៈទាំងនេះគ្រូផលិតឬលើកឡើងសម្រាប់ជាជំនួយក្នុងការរៀន និងបង្រៀន។

**ឃ- សម្ភារៈអេឡិចត្រូនិច**

ក្រៅពីការណែនាំប្រើប្រាស់សម្ភារៈសំខាន់ៗ ទាំងបីខាងលើ អ្នកគ្រូ លោកគ្រូត្រូវមានសមត្ថភាព ក្នុងការប្រើប្រាស់ប្រភេទសម្ភារៈអេឡិចត្រូនិចទំនើបមួយចំនួនទៀតដូចខាងក្រោម៖

- **សម្ភារៈអេឡិចត្រូនិចសម្រាប់ធ្វើបទបង្ហាញ** : សម្ភារៈឧបទេសប្រភេទនេះ មានការទាក់ទងអារម្មណ៍អ្នកសិក្សា
- ឬអ្នកចូលរួមបានជាច្រើន។ សម្ភារៈ នេះទាមទារឱ្យមានការរៀបចំ និងចងក្រងខ្លឹមសារមេរៀន ឬប្រធានបទនានាតាមរយៈការប្រើប្រាស់បច្ចេក វិទ្យាព័ត៌មានទំនើបដោយប្រើប្រាស់កម្មវិធីមួយចំនួនរបស់កុំព្យូទ័រ ម៉ាស៊ីនបញ្ចាំង ព្រមទាំងសម្ភារៈ មួយ ចំនួនទៀតដូចជា ឌីវីឌី ម៉ាញេ វិដេអូ ជាដើម។
- **សម្ភារៈអេឡិចត្រូនិច សម្រាប់ធ្វើការសិក្សាស្រាវជ្រាវ និងផ្តល់ព័ត៌មាន** : សម្ភារៈសម្រាប់ធ្វើការសិក្សាស្រាវជ្រាវមានដូចជាកុំព្យូទ័រ អិុនធឺណិត ហ្វេសប៊ុក តេឡេក្រាម អ៊ីមែល យូធូប និងទូរស័ព្ទជាដើម។សម្ភារៈប្រភេទនេះទាមទារឱ្យគ្រូបង្រៀនមានសមត្ថភាពគ្រប់គ្រាន់ និងចំណេះដឹងពីបច្ចេកវិទ្យាព័ត៌មានឱ្យច្បាស់លាស់។ ការប្រើសម្ភារៈទាំងបានល្អប្រសើរ គឺទាមទារឱ្យ គ្រូបង្រៀនមានចំណេះដឹងផ្នែកភាសាបរទេសថែមទៀត។ នៅក្នុងកម្មវិធីទាំងនេះ យើងអាចមើលឃើញឯកសារជាច្រើនជុំវិញពិភពលោក និងការចែករំលែក។ ការសិក្សាស្រាវជ្រាវដែលប្រើប្រាស់សម្ភារៈទាំង នេះធ្វើឱ្យមានការយល់ដឹងកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាពថែមទៀត។

## ៦- ការវាយតម្លៃ

### ៦.១- គោលបំណងការវាយតម្លៃ

ជាទូទៅការវាយតម្លៃ មានគោលបំណងដូចតទៅ៖

- វាស់កម្រិតចំណេះដឹង បំណិន ឬសមត្ថភាពរបស់សិស្ស ក្រោយពីបានសិក្សាចប់មេរៀន ជំពូក ប្រធានបទ ឬកម្មវិធីសិក្សាតាមថ្នាក់ តាមមុខវិជ្ជា ឬក៏តាមភូមិសិក្សានីមួយៗ។
- វាស់កម្រិតនៃការប្រែប្រួលឬការរីកចម្រើនផ្លូវចិត្ត និងគុណតម្លៃនានា ដូចជាតម្លៃសីលធម៌ ឥរិយាបថ សាមគ្គីភាព ព្រហ្មវិហារធម៌។ល។
- ឆ្លុះបញ្ចាំងពីលទ្ធផលនៃការរៀន និងបង្រៀនដោយផ្តល់ព័ត៌មានត្រឡប់ ក្នុងការជួយគ្រូ សិស្សមាតាបិតាឬអាណាព្យាបាលសិស្ស និងគណៈគ្រប់គ្រង ដើម្បីលើកកម្ពស់គុណភាពនៃការរៀននិងបង្រៀន ឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាពខ្ពស់។

### ៦.២- នានាភាពនៃការវាយតម្លៃ

- ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សតាមកម្រិតថ្នាក់នីមួយៗ
- ការវាយតម្លៃលទ្ធផលសិក្សាធៀបទៅនឹងស្តង់ដាកម្មវិធីសិក្សា
- ការវាយតម្លៃបញ្ចប់ភូមិសិក្សាឬប្រឡងថ្នាក់ជាតិ។ល។
- ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស តាមកម្រិតថ្នាក់នីមួយៗត្រូវធ្វើឡើងទៅតាមដំណាក់៖
  - ✓ ការវាយតម្លៃជាប្រចាំ : ធ្វើឡើងក្នុងពេលកំពុងបង្រៀនមេរៀននីមួយៗ។
  - ✓ ការវាយតម្លៃតាមដំណាក់: ធ្វើឡើងនៅពេលបញ្ចប់ដំណាក់តូចៗនៃមេរៀន ជំពូក ឬផ្នែកនីមួយៗ។ ការវាយតម្លៃនេះមានគោលបំណងត្រួតពិនិត្យមើលដំណើរការរៀននិងបង្រៀន និងពិនិត្យសមត្ថភាពសិស្ស។
  - ✓ ការវាយតម្លៃប្រចាំខែនិងប្រចាំឆមាសៈ ធ្វើឡើងនៅពេលដំណាច់ខែឬបញ្ចប់ឆមាសនីមួយៗនៃឆ្នាំសិក្សា។ ចំពោះតេស្តប្រចាំខែនិងឆមាស គួរធ្វើឡើងដោយមានឧបករណ៍តេស្តរួមគ្នាទៅតាមខណ្ឌ ក្រុង ស្រុក រាជធានី ខេត្ត និងអាចប្រើឧបករណ៍ថ្នាក់ជាតិ។

### ៦.៣- វិធីវាយតម្លៃ

វិធីវាយតម្លៃ អាចធ្វើជាសំណួរផ្ទាល់មាត់ សំណេរ ឬជាការប្រតិបត្តិ ដូចជាការសម្តែង ល្បែងសិក្សា ករណីសិក្សា ស្រាវជ្រាវ។ល។ គ្រូនិងគណៈគ្រប់គ្រងសាលាគួរផ្តល់ការបញ្ជាក់យ៉ាងច្បាស់លាស់ដល់សិស្ស និងមាតាបិតា ឬអាណាព្យាបាលសិស្ស អំពីលទ្ធផលសិក្សា ដែលសិស្សទទួលបាន ទៅតាមដំណាក់នីមួយៗ។ សិស្សគួរតែទទួលបានព័ត៌មានច្បាស់លាស់អំពីចំណុចខ្លាំង ចំណុចខ្សោយ និងជំហានដែលពួកគេត្រូវអភិវឌ្ឍបន្តដើម្បីបង្កើនលទ្ធផលសិក្សារបស់ពួកគេ។

## ៧- តារាងកម្មវិធីសិក្សា

### ៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១០

**បណ្តុំវិទ្យាសាស្ត្រ១៧៥ម៉ និងបណ្តុំវិទ្យាសាស្ត្រសង្គម២១០ម៉**

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង | |
|---|---|---|---|
| | | វិ.សង្គម | វិ.សាស្ត្រ |
| **សមត្ថភាពស្នូល** | | | |
| I. អត្ថបទអក្សរសិល្ប៍ខ្មែរ និងបរទេស | | ០៦ម៉ | ០៤ម៉ |
| ១- រឿងប្រជាប្រិយ<br>២- រឿងបុរាណ<br>៣- រឿងទំនើប<br>៤- រឿងល្ខោន | **វិជ្ជាសម្បទា**<br>- ប្រាប់ពីភាពខុសគ្នារវាងរឿងប្រជាប្រិយ បុរាណ ទំនើប និងរឿងល្ខោន នៃអត្ថបទរឿងខ្មែរ និងបរទេស<br>- ***ប្រាប់ពីវិធីបកស្រាយដោយផ្តល់អំណះអំណាងនិងហេតុផលអំពីគំនិតផ្ទាល់ចំពោះទស្សនៈរបស់អ្នកនិពន្ធ***<br>- ប្រាប់អំពីចំណងជើង ប្រភព ប្រភេទ ចលនា អ្នកនិពន្ធ កាលកំណត់តែង កាលប្រវត្តិ ព្រឹត្តិការណ៍ និងតួអង្គ។<br>**បំណិនសម្បទា**<br>- បង្ហាញពីកាលអាកាស ប្រធានរឿង មូលបញ្ហា ទំនាស់ វិភាគតួអង្គ ឧត្តមគតិរឿង វិធីតែងនិពន្ធ ផ្តើមរឿង ដំណើររឿង និងបញ្ចប់រឿង<br>- ***បកស្រាយដោយផ្តល់អំណះអំណាងនិងហេតុផលអំពីគំនិតផ្ទាល់ចំពោះទស្សនៈរបស់អ្នកនិពន្ធ ។***<br>**ចរិយាសម្បទា**<br>- មានស្មារតីស្រឡាញ់ ឱ្យតម្លៃអក្សរសិល្ប៍និងស្នាដៃអ្នកនិពន្ធ ស្រាវជ្រាវ ដើម្បីទទួលបានពុទ្ធិ បទពិសោធនៃជីវិត និងវិនិច្ឆ័យទស្សនៈ គំនិតអ្នកនិពន្ធដោយផ្សារភ្ជាប់នឹងស្ថានភាពរស់នៅជាក់ស្តែងរបស់ខ្លួន ។ | | |

| | | | |
|---|---|---|---|
| **II. អត្ថបទកំណាព្យ និងចម្រៀង** | | **០៧ម៉** | **០៦ម៉** |
| ១- បទមូលដ្ឋាន<br>២- បទទ្វេមាត្រ<br>៣- ចម្រៀង | **វិជ្ជាសម្បទា**<br>- ប្រាប់ពីរបៀបសូត្រកំណាព្យ និងច្រៀងចម្រៀងតាមបែបបទ<br>- ប្រាប់អំពី ប្រភេទ ប្រភព អ្នកនិពន្ធ កាលកំណត់តែង ចំណាប់ជួន ជួន រណ្ដំ កាព្យមាត្រ ចង្វាក់ សង្គមបរិយាកាស គំនិតសំខាន់ និមិត្តរូប ភាសាច្បាស់លាស់ ភាសារស់រវើក អត្ថន័យ តម្លៃអប់រំ និងភាពខុសគ្នានៃបទកំណាព្យនីមួយៗ ។<br>**បំណិនសម្បទា**<br>- សូត្រកំណាព្យបទមូលដ្ឋាន បទទ្វេមាត្រ និងច្រៀងចម្រៀងតាមបែបបទ<br>- បង្ហាញអំពី សង្គមបរិយាកាស គំនិតសំខាន់ និមិត្តរូប ភាសាច្បាស់លាស់ ភាសារស់រវើក អត្ថន័យ តម្លៃអប់រំ និងភាពខុសគ្នានៃបទកំណាព្យនីមួយៗ<br>- ***បង្ហាញពីរូបារម្មណ៍មួយចំនួនដែលប្រើប្រាស់ ក្នុងអត្ថបទ ដូចជា ចក្ខុរូបារម្មណ៍ សោតរូបារម្មណ៍ ឃានរូបារម្មណ៍ ជីវ្ហារូបារម្មណ៍ កាយរូបារម្មណ៍។ល។***<br>- បង្ហាញពីសារប្រយោជន៍ និងការប្រើប្រាស់បំណិន និងកំណាព្យនីមួយៗ នៅក្នុងស្ថានភាពជាក់ស្ដែង ។<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការសូត្រកំណាព្យ ច្រៀងចម្រៀង ព្រមទាំងស្រឡាញ់ និងអភិរក្សកំណាព្យ និងចម្រៀងខ្មែរ ។ | | |
| **III. អត្ថបទផ្សេងៗ** | | **០៨ម៉** | **០៧ម៉** |
| ១- អត្ថាធិប្បាយ<br>២- ព័ត៌មាន<br>៣- ការឃោសនា<br>៤- សេចក្តីថ្លែងការណ៍<br>៥- វិយោគកថា<br>៦- សុន្ទរកថា<br>៧- សង្កថា<br>៨- អារម្ភកថា<br>៩- បុព្វកថា<br>១០- បាឋកថា | **វិជ្ជាសម្បទា**<br>- ប្រាប់ពីប្រភេទអត្ថបទ ប្រភព ទម្រង់ អ្នកនិពន្ធ ប្រធានបទ គោលបំណង កាលកំណត់តែង គំនិតសំខាន់ ។<br>**បំណិនសម្បទា**<br>- កត់ត្រាចំណុចសំខាន់ៗ សង្ខេប សន្និដ្ឋាន រៀបព្រឹត្តិការណ៍ដែលមានលក្ខណៈស្មុគស្មាញតាមលំដាប់កាលបរិច្ឆេទ<br>- បង្ហាញអត្ថន័យ និងតម្លៃអប់រំ នៃអត្ថបទដែលបានស្ដាប់<br>- វាយតម្លៃគំនិត ព័ត៌មាន ហេតុការណ៍ រឿងរ៉ាវព្រឹត្តិការណ៍ ឬការឃោសនា និងភាពខុសគ្នានៃអត្ថបទ<br>- ***បកស្រាយដោយផ្ដល់អំណះអំណាងនិងហេតុផលអំពីភាពលម្អៀង បុរេនិច្ច័យ និងវិធីអូសទាញឬបញ្ចុះបញ្ចូល***<br>- បង្ហាញពីសារប្រយោជន៍ និងការប្រើប្រាស់បំណិន និងអត្ថបទនីមួយៗ នៅក្នុងស្ថានភាពជាក់ស្ដែង។ | | |

| | | | |
|---|---|---|---|
| | **ចរិយាសម្បទា**<br>- មានទម្លាប់ស្តាប់ដោយយកចិត្តទុកដាក់ មានទំនុកចិត្ត និង ក្នុងការប្រើប្រាស់ព័ត៌មានបានលឺនៅក្នុងជីវភាពជាក់ស្តែង ។ | | |
| | **សមត្ថភាពនិយាយ** | | |
| ១- ការពង្រីកគំនិតដើម្បីផ្តល់សេចក្តីពន្យល់ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីសំនួនពាក្យ និងបែបបទនៃការនិយាយពង្រីកគំនិតដើម្បីផ្តល់សេចក្តីពន្យល់ ។<br>**បំណិនសម្បទា**<br>- ពង្រីកគំនិតដើម្បីផ្តល់សេចក្តីពន្យល់ និងបកស្រាយដោយផ្តល់អំណះអំណាងអំពីប្រធានបទអ្វីមួយ<br>- ពង្រីកគំនិតដើម្បីផ្តល់សេចក្តីពន្យល់ និងការពន្យល់ដោយផ្តល់អំណះអំណាងនៅក្នុងស្ថានភាពជាក់ស្តែង។<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការនិយាយបកស្រាយពន្យល់ និងផ្តល់អំណះអំណាងច្បាស់លាស់ ។ | ០២ម៉ | ០២ម៉ |
| *២- ការការពារប្រធានបទដែលបានបង្ហាញ* | **វិជ្ជាសម្បទា**<br>- *ប្រាប់ពីសំនួនពាក្យ និងបែបបទនៃនិយាយការពារប្រធានបទដែលបានបង្ហាញ ។*<br>**បំណិនសម្បទា**<br>- *ធ្វើការបកស្រាយដើម្បីការពារប្រធានបទដែលបានបង្ហាញ*<br>- *បង្ហាញពីអំណះអំណាងក្នុងការបកស្រាយ ដើម្បីការពារប្រធានបទនៅក្នុងស្ថានភាពជាក់ស្តែង។*<br>**ចរិយាសម្បទា**<br>- *មានទំនុកចិត្ត និងគំនិតច្នៃប្រឌិតក្នុងការនិយាយបកស្រាយដើម្បីការពារប្រធានបទដែលបានបង្ហាញ។* | ០២ម៉ | ០០ម៉ |
| ៣- ការឃោសនា | **វិជ្ជាសម្បទា**<br>- ប្រាប់ពីសំនួនពាក្យ និងបែបបទក្នុងការនិយាយឃោសនា។<br>**បំណិនសម្បទា**<br>- ឃោសនាទាក់ទាញអតិថិជន ឬសាធារណជន<br>- បង្ហាញពីសារប្រយោជន៍នៃការឃោសនាទាក់ទាញអតិថិជន ឬសាធារណជន នៅក្នុងស្ថានភាពជាក់ស្តែង ។<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការនិយាយឃោសនា។ | ០២ម៉ | ០៣ម៉ |

| | | | |
|---|---|---|---|
| ៤- ការធ្វើបទ<br>សម្ភាស | **វិជ្ជាសម្បទា**<br>- ប្រាប់ពីការរៀបចំសំនួនពាក្យនិងបែបបទក្នុងការសម្ភាស ។<br>**បំណិនសម្បទា**<br>- រៀបចំនិងអនុវត្តការធ្វើបទសម្ភាស<br>- បង្ហាញពីសារប្រយោជន៍និងការប្រើប្រាស់ការធ្វើបទសម្ភាស នៅក្នុងស្ថានភាពជាក់ស្តែង ។<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការធ្វើសម្ភាស ចេះប្រើពាក្យគួរសម និង មានទំនាក់ទំនងល្អ ។ | ០២ម៉ | ០២ម៉ |
| *៥- ការចរចា* | **វិជ្ជាសម្បទា**<br>- *ប្រាប់ពីសំនួនពាក្យ និងបែបបទក្នុងការនិយាយចរចា ។*<br>**បំណិនសម្បទា**<br>- *ចរចាដោះស្រាយបញ្ហានៅក្នុងសាលារៀនឬសហគមន៍*<br>- *បង្ហាញពីសារប្រយោជន៍នៃការចរចាដោះស្រាយបញ្ហានៅ ក្នុងស្ថានភាពជាក់ស្តែង ។*<br>**ចរិយាសម្បទា**<br>- *មានទំនុកចិត្តនិងច្នៃប្រឌិតក្នុងការចរចាដោះស្រាយបញ្ហា ។* | ០២ម៉ | ០០ម៉ |
| ៦- ការធ្វើ<br>អត្ថាធិប្បាយ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីការរៀបចំសេចក្តីនិងបែបបទនៃការធ្វើអត្ថាធិប្បាយ។<br>**បំណិនសម្បទា**<br>- រៀបចំនិងធ្វើអត្ថាធិប្បាយក្នុងពិធីផ្សេងៗ និងព័ត៌មាន<br>- បង្ហាញពីសារប្រយោជន៍ នៃការធ្វើអត្ថាធិប្បាយនៅក្នុងស្ថាន ភាព ជាក់ស្តែង។<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្ត និងគំនិតច្នៃប្រឌិតពេលធ្វើអត្ថាធិប្បាយក្នុង ពិធីផ្សេងៗ និងព័ត៌មាន ។ | ០២ម៉ | ០២ម៉ |
| ៧- ការធ្វើវាគ្មិន<br>ក្នុងវេទិកា<br>ផ្សេងៗ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីការរៀបចំ សំនួនពាក្យ និងបែបបទក្នុងការប្រើវោហារ សព្ទពេលធ្វើជាវាគ្មិនក្នុងវេទិកាផ្សេងៗ ។<br>**បំណិនសម្បទា**<br>- ប្រើវោហារសព្ទពេលធ្វើជាវាគ្មិនក្នុងវេទិកាផ្សេងៗ<br>- បង្ហាញពីសារប្រយោជន៍ និងការប្រើប្រាស់ការថ្លែងសន្ទរកថា នៅក្នុងស្ថានភាពជាក់ស្តែង ។<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្ត និងការច្នៃប្រឌិតក្នុងការប្រើវោហារសព្ទពេល ធ្វើជាវាគ្មិនក្នុងវេទិកាផ្សេងៗ ។ | ០២ម៉ | ០២ម៉ |

| | | | |
|---|---|---|---|
| ៨- ការធ្វើបទ បង្ហាញ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីការរៀបចំសំនួនពាក្យ និងបែបបទ ក្នុងការធ្វើបទបង្ហាញ ។<br>**បំណិនសម្បទា**<br>- រៀបចំនិងធ្វើបទបង្ហាញអំពីប្រធានបទអ្វីមួយ<br>- បង្ហាញពីសារប្រយោជន៍ និងការប្រើប្រាស់ការធ្វើបទបង្ហាញនៅក្នុងស្ថានភាពជាក់ស្តែង ។<br>**ចរិយាសម្បទា**<br>- ក្លាហាន និងមានគំនិតច្នៃប្រឌិតក្នុងការធ្វើបទបង្ហាញ ។ | ០២ម៉ | ០២ម៉ |
| *៩- ការបញ្ចេញ ទស្សនៈលើ ប្រធានបទ និងព័ត៌មាន* | **វិជ្ជាសម្បទា**<br>- *ប្រាប់ពីការរៀបចំ សំនួនពាក្យ និងបែបបទក្នុងការនិយាយបញ្ចេញទស្សនៈលើប្រធានបទនិងព័ត៌មាន ។*<br>**បំណិនសម្បទា**<br>- *បញ្ចេញទស្សនៈលើប្រធានបទ និងព័ត៌មាន ។*<br>- *បង្ហាញពីសារប្រយោជន៍នៃការបញ្ចេញទស្សនៈលើប្រធានបទនិងព័ត៌មាននៅក្នុងស្ថានភាពជាក់ស្តែង ។*<br>**ចរិយាសម្បទា**<br>- ***មានទំនុកចិត្តនិងមានគំនិតច្នៃប្រឌិតក្នុងការធ្វើបទបង្ហាញ។*** | ០២ម៉ | ០០ម៉ |
| ១០- ការសម្រប សម្រួល | វិជ្ជាសម្បទា<br>- ប្រាប់ពីការរៀបចំ សំនួនពាក្យ និងបែបបទក្នុងការនិយាយសម្របសម្រួល។<br>បំណិនសម្បទា<br>- ធ្វើការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព<br>- បង្ហាញពីសារប្រយោជន៍នៃការសម្របសម្រួលនៅក្នុងស្ថានភាពជាក់ស្តែង។<br>ចរិយាសម្បទា<br>- មានទំនុកចិត្ត និងច្នៃប្រឌិតក្នុងការធ្វើបទបង្ហាញ។ | ០២ម៉ | ០២ម៉ |
| **សមត្ថភាពអាន** | | | |
| **I. អត្ថបទរឿងដកស្រង់ពីអក្សរសិល្ប៍ខ្មែរ និងបរទេស** | | **១០ម៉** | **០៨ម៉** |
| ១- រឿងប្រជាប្រិយ<br>២- រឿងបុរាណ<br>៣- រឿងទំនើប<br>៤- រឿងល្ខោន | **វិជ្ជាសម្បទា**<br>- ប្រាប់លក្ខណៈសម្គាល់រឿងបែបពុទ្ធនិយម ព្រាហ្មណ៍និយម និងខេមរនិយម<br>- ប្រាប់ចំណងជើង ប្រភព ប្រភេទ ចលនា អ្នកនិពន្ធ កាលកំណត់តែង កាលប្បវត្តិ ព្រឹត្តិការណ៍សំខាន់ៗ នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ។ | | |

| | | | |
|---|---|---|---|
